# ការចូលក្នុងអង្គការពាណិជ្ជកម្មពិភពលោករបស់កម្ពុជា៖
# ភាពប្រឈមប្រថាន និងអត្ថប្រយោជន៍

## សារចំហ

កិច្ចចរចាដែលបានបញ្ចប់នាពេលថ្មីៗ និងការអនុម័តតាមការរំពឹងទុកដើម្បីអោយកម្ពុជាចូលទៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក មិនត្រឹមតែជាសមិទ្ធិផលដ៏ធំធេងសំរាប់សេដ្ឋកិច្ចរបស់កម្ពុជាប៉ុណ្ណោះទេ ក៏ប៉ុន្តែសំរាប់ប្រទេសដែលពុំសូវមានការអភិវឌ្ឍទាំងអស់ ដែលព្យាយាមទាញយកអត្ថប្រយោជន៍ពាណិជ្ជកម្ម។ ប្រទេសទាំងនេះយល់មេរៀនកាលពីពីរទសវត្សរ៍កន្លងទៅ៖ សមាហរណកម្មជាមួយនិងសេដ្ឋកិច្ចពិភពលោកដើម្បីអភិវឌ្ឍន៍។ ប្រទេសទាំងឡាយណាដែលមានអត្រាផលិតផលសរុបក្នុងស្រុក (ផ.ស.ស)ខ្ពស់បំផុត ចូរហៅប្រទេសទាំងនោះថា "សមាហរណករ" ដែល ផ.ស.ស របសគេបានកើនឡើងជាមធ្យម ៣,៥ភាគរយក្នុងមួយឆ្នាំ ក្នុងទសវត្សរ៍ឆ្នាំ១៩៨០ និង ៥ភាគរយក្នុងមួយឆ្នាំក្នុងទសវត្សរ៍ឆ្នាំ១៩៩០ ក្នុងខណៈដែល ផ.ស.ស របស់ប្រទេស "មិនមែនសមាហរណករ" បានកើនឡើងត្រឹមតែ ០,៨ភាគរយ នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ និង ១,៥ភាគរយ នៅក្នុងទសវត្សរ៍ឆ្នាំ១៩៩០។

WTO គឺជាស្ថាប័នមួយដែលមានអំណាចតាមរយៈការប្តេជ្ញារបស់សមាជិករបស់ខ្លួនក្នុងការគ្រប់គ្រងពាណិជ្ជកម្មដែលមានតំលៃរួមមួយចំនួនគឺ៖ ការបើកចំហ តម្លាភាព ភាពប្រាកដប្រជា ការមិនរើសអើង/ពហុភាគីនិយម និងការដោះស្រាយជំលោះដោយផ្អែកលើច្បាប់។ ប្រសិនបើអ្នកគិតគូរអំពីតំលៃទាំងនេះ វាមានចំនុចដូចគ្នាជាច្រើនដែលកម្ពុជាកំពុងព្យាយាមបង្ហាញតាមរយៈការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចរបស់ខ្លួន។ ការចូលរួមក្នុង WTO លើកកំពស់ការចូលទីផ្សារ ហើយក៏បញ្ជូននូវសញ្ញាណដ៏រឹងមាំមួយដែរចំពោះដៃគូពាណិជ្ជកម្ម និងវិនិយោគ អំពីទិសដៅអនាគតរបស់កម្ពុជា។

ក៏ប៉ុន្តែ WTO មិនមែនផ្តល់ផលប្រយោជន៍សព្វបែបយ៉ាងនោះទេ។ ការទាញយកអត្ថប្រយោជន៍ពីការឈានចូលទីផ្សារនឹងទាមទារនូវកំណែទំរង់យ៉ាងច្រើន ដែលហួសលទ្ធភាពរបស់កម្ពុជាដែលបានសន្យាក្នុងកំឡុងពេលចរចា។ ផលិតករក្នុងស្រុករបស់កម្ពុជាជួបប្រទះឧបសគ្គមួយចំនួនលើបញ្ហាពន្ធនាំចេញនាំចូលដែលធ្វើអោយប៉ះពាល់ដល់អត្ថប្រយោជន៍នៃការឈានចូលទីផ្សារ។ លើកឧទាហរណ៍អំពីស្រូវ ដែលជាដំណាំនាំមុខគេក្នុងប្រទេស។ តើទីផ្សារអន្តរជាតិដែលបើកចំហនឹងជួយអ្វីដល់កសិករដែលមិនអាចលក់ដំណាំរបស់ខ្លួនបាន ដោយសារតែអ្នកកិនស្រូវក្នុងស្រុកគ្មានលទ្ធភាពរកទុនបង្វិលបានការបង់ថ្លៃអគ្គិសនីដែលមានតំលៃជាមធ្យមស្មើ៥ដងធៀបនឹងតំលៃអគ្គិសនីនៃប្រទេសក្នុងតំបន់ គ្មានផ្លូវលំទៅកាន់ទីផ្សារ ហើយនិងត្រូវដោះស្រាយចំពោះការត្រួតពិនិត្យច្រើនកន្លែងច្រើនដង និងការបង់លុយខុសច្បាប់នៅកំពង់ផែ? កត្តាទាំងនេះវាជះឥទ្ធិពលដល់ភាពក្រីក្រ គេចាំបាច់ត្រូវតែធ្វើកំណែទំរង់គ្រប់បណ្តាញនិងនៅក្នុងព្រំដែន។ គោលនយោបាយពាណិជ្ជកម្មគឺជាជំហានដំបូងដ៏សំខាន់មួយ ក៏ប៉ុន្តែវាក៏មិនមែនជាជំហានចុងក្រោយដែរ។

គ្មានប្រព័ន្ធពាណិជ្ជកម្មពិភពលោកមួយណាដែលល្អឥតខ្ចោះនោះទេ។ ប្រទេសជឿនលឿនជាច្រើនប្រកាន់យកការកំណត់ពន្ធគយខ្ពស់ឬរនាំងមិនមែនពន្ធ (គោលនយោបាយការពារ) ដែលបិទទីផ្សារសំរាប់ផលិតផលនានា ដែលកម្ពុជាចង់នាំចេញ។ WTO ផ្តល់នូវយន្តការមួយសំរាប់ដោះស្រាយបញ្ហាបែបនេះ ហើយខ្ញុំជឿជាក់ថាកម្ពុជានឹងក្លាយទៅជាសំលេងថ្មីដ៏សំខាន់មួយនៅក្នុងវេទិកាតំណាងអោយផលប្រយោជន៍របស់ប្រទេសដែលពុំសូវមានការអភិវឌ្ឍទាំងអស់។ គំនិតថ្មីស្តីអំពីបញ្ហាប្រាក់ឧបត្ថម្ភលើកសិកម្មគឺជាឧទាហរណ៍មួយ។ បរិស្ថានក្រោយចូលក្នុង WTO នឹងផ្តល់រង្វាន់ដល់ក្រុមហ៊ុនដែលមានលក្ខណៈប្រកួតប្រជែងច្រើនជាង ហើយពិន័យដល់ក្រុមហ៊ុនដែលគ្មានលក្ខណៈប្រកួតប្រជែង។ សូម្បីតែនៅក្នុងសម័យអន្តរកាលដែលបានរៀបចំដោយអ្នកចរចារបស់កម្ពុជា ការចូលក្នុង WTO លប់បំបាត់ចោលឧបសគ្គភ្លាមៗចំពោះវិស័យឯកជន។ វាជាការលើកទឹកចិត្តខ្លាំងណាស់ចំពោះការកត់សំគាល់ថា WTO បានធ្វើកំណែទំរង់។ ទេសរដ្ឋមន្ត្រីពាណិជ្ជកម្មនាពេលថ្មីៗនេះបានកត់សំគាល់ថា រដ្ឋាភិបាលកំពុងប្រើប្រាស់ WTO ធ្វើជាកត្តាលិករមួយដើម្បីជំរុញកិច្ចការផ្សេងៗគ្នាចំនួន ៩៨ ប្រភេទ ដែលនឹងត្រូវចាប់អនុវត្តដោយក្រសួង និងទីភ្នាក់ងារចំនួន ២០ ផ្សេងៗគ្នាត្រឹមឆ្នាំ២០០៦។

## ចំលើយចំពោះសំណួរជាក់លាក់នានា:

### ១-តើឧស្សាហកម្មណាដែលនឹងត្រូវប៉ះពាល់ និងដោយរបៀបណា?

ពាណិជ្ជកម្មមានឥទ្ធិពលលើស្ទើរគ្រប់ឧស្សាហកម្ម ជាពិសេសចាប់តាំងពីកម្ពុជាបានបើកចំហសេដ្ឋកិច្ច។ ក៏ប៉ុន្តែ កម្ពុជាក៏មានមូលដ្ឋានឧស្សាហកម្មតូចចង្អៀតណាស់ដែរ ដែលគ្របដណ្តប់ដោយឧស្សាហកម្មមួយ គឺ វិស័យកាត់ដេរ។ វិស័យកាត់ដេរ គឺជាការព្រួយបារម្ភរបស់មនុស្សជាច្រើន ពីព្រោះវិស័យនេះបានប្រើប្រាស់កម្មករចំនួន ២៤០.០០០នាក់ និងរហូតដល់ ១លាននាក់ពឹងផ្អែកលើប្រាក់ចំណូលរបស់ពួកគេ។ ក្រោមកិច្ចព្រមព្រៀងរបស់ WTO ស្តីអំពីវាយនភ័ណ្ឌ និងសំលៀកបំពាក់ (ATC) ពាណិជ្ជកម្មកាត់ដេរអន្តរជាតិ ត្រូវបានគ្រប់គ្រងតាមរយៈកូតា។ ក្រោមកិច្ចព្រមព្រៀងទ្វេភាគីមួយ ជាមួយទីផ្សារសំខាន់ៗនានា កម្ពុជាទទួលបានកូតាដែលទាក់ទាញដល់ឧស្សាហកម្ម ដើម្បីវិនិយោគនិងរីកលូតលាស់។ សហរដ្ឋអាមេរិក បានផ្សារភ្ជាប់បរិមាណកូតាទាំងនេះទៅនឹងការទទួលខុសត្រូវរួមរបស់សង្គម ហើយកូតាទាំងនេះត្រូវបានពង្រីកព្រមគ្នាជាមួយនិងប្រព័ន្ធដែលបានកែលំអ។ នៅពេលដែល ATC ត្រូវបានលប់ចោលជាចុងក្រោយនៅចុងឆ្នាំ២០០៤ សមាជិក WTO ដូចកម្ពុជា នឹងមិនត្រូវបានគេរឹតកូតាទៀតទេ។ នៅក្នុងរយៈពេលខ្លីនេះ កម្ពុជាអាចមើលឃើញការកើនឡើងនៃវិនិយោគទុន ដោយសាររោងចក្រកាត់ដេររបស់ប្រទេសដែលមិនមែនជាសមាជិក WTO (ដែលនឹងនៅតែអាស្រ័យលើកូតា) ចូលមកប្រទេសកម្ពុជា។ នៅក្នុងរយៈពេលវែង បើគ្មានការកែទំរង់ គំនាបតម្លៃអាចបង្ខំអោយមានការរួបរួមគ្នា។

វាជាការត្រឹមត្រូវចំពោះការសន្មតទុកជាមុនថា វិស័យកាត់ដេរក្រោយឆ្នាំ២០០៥ នឹងប្រហែលជាដើរតាមគំរូនៃការនាំចេញដែលគ្មានកូតានាពេលបច្ចុប្បន្នទៅកាន់សហរដ្ឋអាមេរិក។ កម្ពុជាបានលក់ក្រៅកូតាក្នុងបរិមាណច្រើនជាងក្នុងកូតា ហើយពាណិជ្ជកម្មដែលគ្មានកូតាបានកើនឡើងយ៉ាងលឿន។ ក៏ប៉ុន្តែ ថ្លៃសំរាប់ផលិតផលដែលកំហិតដោយកូតាស្ទើរតែមានតំលៃ៥ដង ខ្ពស់ជាងតំលៃផលិតផលដែលគ្មានកូតា។ លើសពីនេះទៀត តំលៃសំរាប់ការលក់ដែលគ្មានកូតាបានថយចុះជាបន្តបន្ទាប់ចាប់តាំងពីឆ្នាំ២០០០មក ហើយសព្វថ្ងៃនេះតំលៃនេះឋិតនៅលើ១ដុល្លាក្នុងមួយម៉ែត្រការ៉េ។ ដោយសារតែបរិមាណកើនឡើង ហើយថ្លៃលក់ថយចុះ ឧស្សាហកម្មនេះទំនងជាអាច (ក) ពឹងផ្អែកយ៉ាងខ្លាំងទៅលើភាពប្រកួតប្រជែងនៃថ្លៃ (ខ) ក្លាយទៅជាពាណិជ្ជកម្មដែលជំរុញដោយបរិមាណដែលមានទំហំធំជាងមុន (គ) ផ្តោតអារម្មណ៍ច្រើនជាងទៅលើរោងចក្រធំៗមួយចំនួនតូចដែលមានលទ្ធភាពអាចផ្តល់នូវសេវាកម្មទូលំទូលាយក្នុងតំលៃទាបគ្របដណ្តប់លើវិស័យនេះ និង (ឃ) បង្រួបបង្រួមពាណិជ្ជកម្មឆ្លងកាត់ព្រំដែន នៅពេលដែលទំហំសេដ្ឋកិច្ចកាន់តែមានសារៈសំខាន់ជាងការបែងចែកកូតា។ នៅពេលដែលគ្មានកត្តាណាមួយក្នុងចំណោមកត្តាទាំងនេះត្រូវបានគេរំពឹងទុកថាមានលក្ខណៈបន្ទាន់ទេនោះ វាមិនច្បាស់លាស់ថាតើកម្ពុជានឹងឋិតនៅជាប្រទេសនាំចេញផលិតផលកាត់ដេរដ៏ធំបានយូរប៉ុណ្ណានោះទេ ប្រសិនបើខ្លួនមិនបង្កើនភាពប្រកួតប្រជែង រួមទាំងការកាត់បន្ថយថ្លៃ និងការរក្សាទុកនូវអត្ថប្រយោជន៍លើការទទួលខុសត្រូវសង្គមរួមគ្នា (មានភាពស្មើគ្នាលើការងារ មិនប្រើប្រាស់ក្មេងក្រោមអាយុជាកម្មករ មានសហជីព និងមានប្រាក់កំរៃអតិបរមា ។ល។)។

ក៏ប៉ុន្តែ បញ្ហាវិស័យកាត់ដេរមានសារៈប្រយោជន៍មួយផ្សេងទៀត។ វិស័យនេះបង្ហាញអោយឃើញថាការឈានចូលទីផ្សារនាំមកនូវការរីកចំរើន។ តាមរយៈ WTO ដំណើរការហ្មត់ចត់នៃកិច្ចព្រមព្រៀងទ្វេភាគីសំរាប់ផលិតផលនីមួយៗ និងទីផ្សារសំខាន់ទាំងអស់ត្រូវបានដាក់ជំនួសដោយប្រព័ន្ធមួយដែលផ្អែកលើច្បាប់ ដែល (តាមរយៈយន្តការនៃការមិនរើសអើង) ផ្តល់អោយកម្ពុជាភ្លាមនូវលក្ខខ័ណ្ឌអនុគ្រោះបំផុតក្នុងចំណោមប្រទេសដែលជាសមាជិកទាំងអស់។

ដូច្នេះ អ្នកអាចមើលឃើញថា អត្ថន័យសេដ្ឋកិច្ចនៃការចូល WTO គឺមិនមែនសំដៅចំពោះឧស្សាហកម្មពិសេសទេ ក៏ប៉ុន្តែគឺដើម្បីគាំទ្រដល់ការពង្រីកឧស្សាហកម្មតាមរយៈការអនុវត្តមេរៀនដែលទទួលបានពីឧស្សាហកម្មកាត់ដេរៈ ឱកាសឈានចូលទីផ្សារអាចជាការលើកទឹកចិត្តមួយដ៏ខ្លាំងក្លាចំពោះការអភិវឌ្ឍ។

**២-តើកម្ពុជានឹងត្រូវធ្វើអ្វីខ្លះដើម្បីគោរពតាមច្បាប់របស់ WTO?**

ចំលើយនេះមិនមែនខ្លីទេ ទោះបីជា WTO មានកិច្ចព្រមព្រៀងមូលដ្ឋានជាច្រើនដែលបានជំនួសកិច្ចព្រមព្រៀងទូទៅស្តីអំពីពន្ធគយនិងពាណិជ្ជកម្ម (GATT)ក៏ដោយ ក៏កាតព្វកិច្ចនៃកិច្ចព្រមព្រៀងរបស់ប្រទេសជាសមាជិកត្រូវបានគេកំណត់ជាក់លាក់តាមរយៈដំណើរការដែលបានចរចាដែលមានលក្ខណៈពិសេសចំពោះសមាជិកថ្មីនីមួយៗ។

កាតព្វកិច្ចទូទៅគឺចង់សំដៅទៅលើការគោរពតាមគោលការណ៏ដែលខ្ញុំបានលើកខាងលើ។ កម្ពុជាត្រូវតែអនុវត្តតាមគោលនយោបាយពាណិជ្ជកម្មដូចគ្នាចំពោះសមាជិក WTO ទាំងអស់ (លើកលែងចំពោះកិច្ចព្រមព្រៀងតំបន់) និងត្រូវតែលើកទឹកចិត្តទំនិញបរទេសតិចជាងទំនិញដែលផលិតក្នុងស្រុក នៅពេលដែលកំពុងអនុវត្តនិយ័តកម្មដែលទាក់ទងទៅនឹងពាណិជ្ជកម្ម (ដូចជាស្តង់ដារ សុវត្ថិភាពចំណីអាហារ)។ កម្ពុជាក៏បានសន្យាផងដែរថាមិនប្រើប្រាស់កូតាឬក៏ប្រាក់ឧបត្ថម្ភសំរាប់ការនាំចេញទេ។ ជាការជំនួសមកវិញ កម្ពុជាត្រូវបានគេអនុញ្ញាតិអោយប្រើប្រាស់ពន្ធគយដែលមានតម្លាភាពជាង។ កម្ពុជាបានសន្យាថាមិនបង្កើនកំរិតនៃពន្ធគយធម្មតាលើកំរិតពន្ធគយដែលបានចរចាជាមួយសមាជិក WTO ដទៃៗទៀតទេ។

កាតព្វកិច្ចជាក់លាក់នានាកាន់តែមានលក្ខណៈគួរអោយចាប់អារម្មណ៏។ ករណីប្រទេសកម្ពុជា ក្រុមការងារដែលដឹកនាំដោយប្រធានក្រុមចរចានិងលោក ចម ប្រសិទ្ធិ រដ្ឋមន្ត្រីពាណិជ្ជកម្ម និងលោក សុខ ស៊ីផាន់ណា រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម បានចរចាជាមួយ "ក្រុមការងារ"[១] យ៉ាងល្អិតល្អន់ចាប់តាំងពីឆ្នាំ ១៩៩៩មក។ ក្នុងថេរវេលានេះ សមាជិកនៃក្រុមការងារបានលើកឡើងនូវបញ្ហានិងសំណួរមួយចំនួនដើម្បីបញ្ជាក់អោយបានច្បាស់លាស់ថាតើកម្ពុជាកំពុងតែចាត់វិធានការចាំបាច់ដើម្បីក្លាយជាសមាជិកមួយដែលមានសមត្ថភាពនិងមានការទទួលខុសត្រូវរបស់សហគមន៍ពាណិជ្ជកម្មពិភពលោកដែរឬអត់។ នៅថ្ងៃទី ២២ ខែកក្កដា ក្រុមការងារនេះបានបង្ហាញថា រាល់បញ្ហាដែលពុំទាន់ដោះស្រាយរួចត្រូវបានដោះស្រាយ ហើយកម្ពុជាត្រូវបានគេអញ្ជើញអោយចូលរួមក្នុងសន្និសីទថ្នាក់រដ្ឋមន្ត្រីនៅទីក្រុងកាន់គុននាខែ កញ្ញា ឆ្នាំ ២០០៣។ សេចក្តីសង្ខេបខាងក្រោមមើលទៅមានសារៈសំខាន់ចំពោះអនុសាសន៏វិជ្ជមានរបស់ក្រុមការងារៈ

- កិច្ចការរបស់កម្ពុជាឆ្ពោះទៅរកស្ថេរភាពម៉ាក្រូសេដ្ឋកិច្ចពឹងផ្អែកលើអត្រាប្តូរប្រាក់ដែលមានលក្ខណៈប្រែប្រួល
- ការគ្រប់គ្រងវិនិយោគទុននិងពន្ធថ្មី រួមទាំងច្បាប់វិនិយោគទុនដែលបានធ្វើវិសោធនកម្ម
- ការប្តេជ្ញាចិត្តដើម្បីបន្តធ្វើកំណែទំរង់តុលាការនិងច្បាប់ រួមទាំងការបង្កើតតុលាការពាណិជ្ជកម្មនិងច្បាប់សំខាន់ៗមួយចំនួនដែលកំពុងដំណើរការ ដូចជាច្បាប់និតិវិធីស៊ីវិល ច្បាប់ពាណិជ្ជកម្ម និងច្បាប់ក្ស័យធន
- តម្លាភាពនិងកំណែទំរង់ដែលបានបន្តដែលទាក់ទងទៅនឹងសហគ្រាសដែលគ្រប់គ្រងដោយរដ្ឋ និងថ្លៃដែលគ្រប់គ្រងដោយរដ្ឋ
- កំណែទំរង់ការគ្រប់គ្រងអាជ្ញាប័ណ្ណនាំចូល
- កំណែទំរង់ពន្ធគយនិងការកំណត់ថ្លៃ និងខចែងស្តីពីយន្តការដោះស្រាយជំលោះ
- ការអនុវត្តភ្លាមៗនូវកិច្ចព្រមព្រៀងស្តីពីវិធានការវិនិយោគទុនដែលទាក់ទងទៅនឹងពាណិជ្ជកម្ម (TRIMS)
- ការអនុវត្តច្បាប់នៃកិច្ចព្រមព្រៀងដើមរបស់ WTO ត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០០៥

---

[១] ប្រធានក្រុមការងារគឺលោក Andrea Meloni នៃប្រទេសអ៊ីតាលី និងសមាជិកក្រុមការងារ មានប្រទេសអូស្ត្រាលី កាណាដា ចិន សហភាពអឺរ៉ុប ឥណ្ឌា ជប៉ុន កូរ៉េ ម៉ាឡេស៊ី ញ៉ូហ្សេឡង់ សឹង្ហបុរី ចិនតៃប៉ិ ថៃ សហរដ្ឋអាមេរិក និងវេណេស៊ុយអេឡា។

- ការអនុវត្តច្បាប់ស្តីពីកម្មសិទ្ធិបញ្ញាដែលទាក់ទងទៅនឹងពាណិជ្ជកម្ម (TRIPS) ត្រឹមថ្ងៃទី ០១ ខែមករា ឆ្នាំ ២០០៧
- ការអនុវត្តកិច្ចព្រមព្រៀងស្តីពីការវាយតំលៃគយរបស់ WTO ត្រឹមថ្ងៃទី ០១ ខែមករា ឆ្នាំ២០០៩
- ការប្តេជ្ញាចិត្តដើម្បីផ្សព្វផ្សាយច្បាប់និងនិយ័តកម្មនៅលើវិបសាយតាមតំរូវការរបស់ WTO
- បន្ថយប្រាក់ឧបត្ថម្ភសំរាប់ការនាំចេញសំរាប់កសិកម្មអោយនៅត្រឹមសូន្យ

នេះគឺជាតារាងបញ្ជីមួយផ្នែក ហើយបញ្ចេញមិនទាន់អស់សេចក្តីនៅឡើយទេ។ ដើម្បីពន្យល់អោយបានច្បាស់លាស់ជាងនេះទៀតលើផលប៉ះពាល់នេះ ខ្ញុំសូមលើកឧទាហរណ៍មួយ គឺកំណែទំរង់លើការគ្រប់គ្រងអាជ្ញាប័ណ្ណនាំចូល។ គេដឹងថាកម្ពុជាបានប្រើប្រាស់ការផ្តល់អាជ្ញាប័ណ្ណនាំចូលដើម្បីត្រួតពិនិត្យពាណិជ្ជកម្មលើផលិតផលមួយចំនួន រួមទាំងឱសថកម្ម ជី/ថ្នាំសំលាប់សត្វល្អិត និងសំភារៈសំណង់មួយចំនួន។ តាមដែលយើងបានដឹងនៅជុំវិញពិភពលោក ការទាមទារអាជ្ញាប័ណ្ណនិងការកំហិតលើការនាំចូលមិនត្រឹមតែបានបង្កើនតំលៃក្នុងស្រុកប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កើតនូវឳកាសសំរាប់អំពើពុករលួយដោយធ្វើអោយមនុស្សងាកទៅប្រព្រឹត្តិអំពើរត់ពន្ធ ស៊ីសំណូកឬក្លែងបន្លំផលិតផលដើម្បីបំពេញតំរូវការខ្ពស់ដែលបង្កើតដោយការគ្រប់គ្រងបែបនេះ។ ត្រឡប់ទៅនិយាយអំពីបញ្ហាស្រូវវិញ យើងដឹងតាមការត្រួតពិនិត្យតំលៃថាតំរូវការអាជ្ញាប័ណ្ណមានន័យថា មានក្រុមហ៊ុនចំនួន ៥ប៉ុណ្ណោះ ដែលត្រូវបានអនុញ្ញាតិអោយនាំជីចូល។ តាមការពិនិត្យបន្ថែមទៀត យើងបានរកឃើញថា កសិករកម្ពុជាបានចំណាយប្រាក់៣ដងលើជី ច្រើនជាងកសិករថៃ ហើយទិន្នផលរបស់ពួកគាត់នៅតែបានទាបជាង១០ភាគរយ។ យើងបានវិភាគលើបញ្ហានេះបន្ថែមបន្តិចបន្តួចទៀត ដូចជាការទិញជីមួយចំនួនៅក្នុងទីផ្សារក្នុងស្រុក ហើយបានដឹងថាពាណិជ្ជករក្នុងស្រុកបានកាត់បន្ថយជីប្រមាណ៧០ភាគរយ ដើម្បីបង្កើនប្រាក់ចំណេញរបស់ពួកគេ។ ដូច្នេះ គោលនយោបាយនេះជាចុងក្រោយកំពុងកាត់បន្ថយភាពប្រកួតប្រជែងលើការនាំចេញសំរាប់កសិករកម្ពុជា ហើយដូច្នេះ វានឹងរួមចំណែកក្នុងភាពក្រីក្រ។ ការកាត់បន្ថយឱសថកម្មរួមទាំងអង់ទីប្យូទិចបានក្លាយទៅជាការព្រួយបារម្ភចំពោះសុខភាពសាធារណៈ។ ចំនុចសំខាន់នៃបញ្ហាទាំងពីរនេះគឺវិធីដែលកម្ពុជាគ្រប់គ្រងសិទ្ធិពាណិជ្ជកម្មដែលកម្ពុជាបានយល់ព្រមធ្វើកំណែទំរង់នៅក្នុងកិច្ចពិភាក្សារបស់ WTO។

ដំណើរការនៃការក្លាយខ្លួនជាសមាជិក WTO បានលើកកំពស់ទស្សនៈវិស័យសំរាប់កសិករ និងអ្នកប្រើប្រាស់ តាមការចំណាយរបស់ក្រុមហ៊ុន និងពាណិជ្ជករទាំងនោះដែលបានទទួលអាជ្ញាប័ណ្ណ ឬដែលបានព្យាយាមយកផលប្រយោជន៍លើកំហុសនៃការគ្រង់គ្រងអាជ្ញាប័ណ្ណ។ អត្ថប្រយោជន៍ដែលទទួលបានពីទស្សនៈវិស័យអភិវឌ្ឍន៍មានលក្ខណៈវិជ្ជមាន។

**៣-តើការចូល WTO មានគុណសម្បត្តិ និងគុណវិបត្តិអ្វីខ្លះ?**

មានគុណសម្បត្តិជាច្រើនក្នុងការចូល WTO ក៏ប៉ុន្តែ ខ្ញុំនឹងកំរិតការអធិប្បាយរបស់ខ្ញុំត្រឹមគុណសម្បត្តិបីយ៉ាង និងគុណវិបត្តិបីយ៉ាង។

**គុណសម្បត្តិៈ**

- **ឱកាសចូលទីផ្សារៈ** តាមរយៈការចូលក្នុង WTO កម្ពុជានឹងត្រូវបានសមាជិកទាំងអស់ចាត់ទុកថាជាប្រទេសដែលទទួលបានឋានៈអនុគ្រោះបំផុត ហើយមិនអាចត្រូវបានគេរើសអើងទេ ដោយយោងទៅតាមគោលការណ៏និងច្បាប់ឋិតនៅក្រោមប្រព័ន្ធពាណិជ្ជកម្ម។ គុណសម្បត្តិនេះផ្តល់នូវឱកាសចូលទីផ្សារកំរិតខ្ពស់សំរាប់ផលិតផលមួយចំនួនធំ និងប្រទេសមួយចំនួនធំ គឺជាសមិទ្ធិផលមួយដែលពិបាកប្រើប្រាស់ពេលវេលាដោយផ្អែកលើមូលដ្ឋានទ្វេភាគីឬតំបន់។
- **ការកសាងសមត្ថភាពៈ** ការទាញយកអត្ថប្រយោជន៏ពី WTO ទាមទារនូវសេវាសាធារណៈដែលមានជំនាញ និងវិស័យឯកជនដែលមានលក្ខណៈឆ្លើយតប និងវិស័យសាធារណៈដែលមានចំណេះដឹង។ កម្ពុជាមានក្រុមចរចាដែលមានសមត្ថភាព វិនិច្ឆ័យតាមលទ្ធផល និងចាំបាច់ត្រូវប្រតិបត្តិអោយបានល្អនៅក្នុងរដ្ឋាភិបាល និងនៅក្នុងខេត្ត។ ដើម្បីគាំទ្រដល់ការកសាងសមត្ថភាព កម្ពុជាគឺជាប្រទេសមួយក្នុងចំណោមប្រទេសសាកល្បងចំនួនបីដែលត្រូវទាញយកអត្ថប្រយោជន៏ពីក្របខ័ណ្ឌរួមស្តីពីជំនួយបច្ចេកទេសដែលទាក់ទងទៅនឹងពាណិជ្ជកម្ម (IF) ដែលជាផលិតផលរួមគ្នាមួយរវាងអង្គការអន្តរជាតិចំនួន ៦ រួមទាំងធនាគារពិភពលោកផង។ ថ្មីៗនេះ សិក្ខាសាលាមួយស្តីអំពីក្របខ័ណ្ឌរួមនេះ ត្រូវបានប្រារព្ធធ្វើឡើងនាទីក្រុងភ្នំពេញ ដើម្បីកសាងសមត្ថភាពរបស់មន្ត្រីនានានៅក្នុងប្រទេសឡាវ និងកម្ពុជា ហើយឯកសារជាភាសាខ្មែរ និងភាសាអង់គ្លេសស្តីអំពីពាណិជ្ជកម្មត្រូវបានដាក់បង្ហាញរួមគ្នា។ ក្រសួងពាណិជ្ជកម្មកំពុងបង្កើតរបាយការណ៏វិភាគដើម្បីអោយពាណិជ្ជករបរទេសយល់អោយបានឆាប់រហ័សអំពីគោលនយោបាយពាណិជ្ជកម្ម និងរចនាសម្ព័ន្ធទីផ្សាររបស់កម្ពុជា ហើយវិស័យឯកជនរបស់កម្ពុជានឹងមានលទ្ធភាពអាចត្រួតពិនិត្យរបាយការណ៏វិភាគពាណិជ្ជកម្មនៅលើទីផ្សារបរទេសបាន។
- **អភិបាលកិច្ចៈ** ដូចដែលបានពិពិណនាខាងលើ ការកាត់បន្ថយអាជ្ញាប័ណ្ណទីផ្សារមិនត្រឹមត្រូវនិងពន្ធគយនឹងលប់បំបាត់ចោលនូវប្រភពនៃអំពើពុករលួយ។ ក៏ប៉ុន្តែ អត្ថប្រយោជន៏នៃអភិបាលកិច្ចបានរំលងផុតប្រទេសកម្ពុជានិងបានរំលងអាជ្ញាប័ណ្ណនិងកូតា។ បញ្ហាជាច្រើនដែលបានលើកឡើងដោយក្រុមការងារគឺអំពីបញ្ហាអភិបាលកិច្ចនិងតម្លាភាព ហើយទាមទារនូវការឆ្លើយតបដូចជាការបញ្ចូលច្បាប់និងនិយ័តកម្មរបស់ខ្លួននៅលើវិបសាយ ការបើកចំហវិស័យនានាដូចជា ទូរគមនាគមន៏ដើម្បីការប្រកួតប្រជែង។ ដូចគ្នានេះដែរ កម្ពុជានឹងមានលទ្ធភាពអាចធ្វើអធិការកិច្ចនិងប្រជែង តាមរយៈច្បាប់របស់ WTO គោលនយោបាយពាណិជ្ជកម្មដែលទទួលយកដោយប្រទេសផ្សេងៗ។

**គុណវិបត្តិ**

- **ការកែតំរូវ:** ច្បាស់លាស់ណាស់នឹងមានការកែតំរូវលើថ្លៃ នៅពេលដែលកម្ពុជាបើកចំហទីផ្សាររបស់ខ្លួនចំពោះក្រុមហ៊ុនទាំងឡាយដែលទទួលស្គាល់ពីបរិស្ថានប្រកួតប្រជែងច្រើន និងមុនពេលដែលកម្ពុជាមានឱកាសអភិវឌ្ឍន៍ស្ថាប័នជាច្រើនដែលគាំទ្រជាសកលដល់វិស័យឯកជន។ កង្វះខាតជំនឿទុកចិត្តលើពាណិជ្ជកម្ម ហេដ្ឋារចនាសម្ព័ន្ធច្បាប់ ការផ្គត់ផ្គង់ បណ្តាញព័ត៌មានទីផ្សារ សមាគមន៍ឧស្សាហកម្ម ស្ថាប័នអភិវឌ្ឍន៍ជំនាញ ស្ថាប័នពិនិត្យគុណភាព និងថ្លៃធ្វើពាណិជ្ជកម្មខ្ពស់ធានាថាក្រុមហ៊ុនក្នុងស្រុកជាច្រើនមិនអាចប្រកួតប្រជែងភ្លាមៗបានទេ។ វាប្រាកដជា នឹងមានការបាត់បង់ការងារនៅក្នុងរយៈពេលខ្លី នៅពេលដែលការនាំចូលប៉ះពាល់ដល់ផលិតកម្មក្នុងស្រុកមួយចំនួន។ កម្ពុជាត្រូវការរយៈពេលកំរិតទីផ្សារយូរប៉ុណ្ណា បញ្ហាកែតំរូវក៏វានឹងមានលក្ខណៈធ្ងន់ធ្ងរប៉ុណ្ណោះដែរ។
- **ថ្លៃ:** កាតព្វកិច្ចទាំងនេះទាមទារអោយកម្ពុជាចំណាយធនធានហិរញ្ញវត្ថុ និងធនធានមនុស្សដ៏ច្រើនលើការកែទំរង់។ ដើម្បីចាប់យកវិស័យមួយ ការអនុវត្ត TRIPS ត្រឹមឆ្នាំ២០០៧ នឹងទាមទារនូវការពិនិត្យសើរើឡើងវិញជាទូទៅ និងការសរសេរច្បាប់របស់កម្ពុជាឡើងវិញ។ នៅក្នុងករណីមួយចំនួន រដ្ឋាភិបាលអាចចាំបាច់ត្រូវបង្កើតទីភ្នាក់ងារថ្មីៗ ឬរៀបចំទីភ្នាក់ងារដែលមានស្រាប់ឡើងវិញ ផ្គត់ផ្គង់បរិក្ខាឯកទេស និងបង្កើនការបណ្តុះបណ្តាលមន្ត្រីរដ្ឋាភិបាល។ កំណែទំរង់ទាំងនេះនឹងប្រកួតប្រជែងជាមួយនិងអាទិភាពគោលនយោបាយសាធារណៈដទៃទៀតសំរាប់ធនធានកម្រររបស់រដ្ឋាភិបាល។ អាស្រ័យហេតុនេះ កម្ពុជាបាលទទួលរយៈពេលកែតំរូវនិងបង្កើត សំរាប់ការប្តេជ្ញារបស់ខ្លួន។
- **ភាពបត់បែន:** តាមរយៈការចូលក្នុង WTO ដែលមានដំណើរការនិងច្បាប់ដែលគេទទួលស្គាល់ វាមានការដោះដូរទំនិញដែលមិនអាចចៀសផុតដែលទាក់ទងទៅនឹងសេរីភាពក្នុងការកំណត់គោលនយោបាយនានា ជាពិសេសគោលនយោបាយទាំងឡាយណាដែលអាចផ្ទុយទៅនឹងតំលៃនិងច្បាប់សំខាន់ៗរបស់ស្ថាប័ននេះ។ ឧទាហរណ៍ កម្ពុជា នឹងលែងមានសិទ្ធិសេរីភាពក្នុងការផ្តល់នូវឱកាសចូលទីផ្សារទៅកាន់ប្រទេសមួយចំនួនតូចតាមការចំណាយរបស់សមាជិកដទៃៗទៀតរបស់ WTO ឬក៏ផ្តល់នូវការការពារពន្ធគយក្នុងកំរិតខ្ពស់លើសពីអ្វីដែលបានចរចាទៀតហើយ។ យើងគិតថា លទ្ធផលសំរេចមានលក្ខណៈវិជ្ជមានណាស់សំរាប់កម្ពុជា ហើយកាន់តែមានលក្ខណៈវិជ្ជមានថែមទៀត ប្រសិនបើវិស័យកំណែទំរង់ពាក់ព័ន្ធនានាត្រូវបានដោះស្រាយ។

**៤-តើនរណានឹងបានទទួលផលច្រើនជាងគេបំផុត ហើយនរណានឹងត្រូវទទួលរងគ្រោះជាងគេបំផុតពីការចូល WTO?**

អ្នកទទួលផលច្រើនជាងគេបំផុតពីការចូល WTO គឺទំនងជាពលរដ្ឋសាមញ្ញរបស់កម្ពុជាដែលជាអ្នកប្រើប្រាស់ និងជាឧស្សាហកម្មតូចតាចដែលបំរើដល់ពួកគេ ដែលនឹងជួបប្រទះជំរើសជាច្រើននិងថ្លៃផលិតផលនាំចូលទាបជាង ហើយនិងផលិតផលក្នុងស្រុកធៀបនិងបរិមាណនាំចូលមួយចំនួន។

អ្នកទទួលផលសំខាន់ទីពីរ គឺវិស័យឯកជន និងកម្មកររបស់កម្ពុជា ជាពិសេសនៅពេលដែលបរិយាកាសវិនិយោគមានការកែលំអ ហើយស្ថាប័នគាំទ្រវិស័យឯកជនត្រូវបានបង្កើតឡើង។ ក៏ប៉ុន្តែ រូបភាពនៅទីនេះមានលក្ខណៈជាកំលាំងជំរុញដែលពឹងផ្អែកលើកំណែទំរង់បន្ថែមទៀត និងការឆ្លើយតបរបស់វិស័យឯកជនចំពោះកំណែទំរង់ទាំងនោះជាចុងក្រោយ។ ថ្មីៗនេះ យើងបានធ្វើការស្ទាបស្ទង់លើសហគ្រាសចំនួន៥០០ លើផលិតភាពនិងការវាយតំលៃបរិយាកាសវិនិយោគ ហើយយើងបានរកឃើញថាមានតែ១៦ភាគរយប៉ុណ្ណោះដែលជាអ្នកនាំចេញពិតប្រាកដ ក៏ប៉ុន្តែ មួយភាគធំនាំចូលវត្ថុធាតុដើមផលិតកម្មរបស់ខ្លួនមួយចំនួន។ អ្នកដែលនាំចេញឬនាំចូលពិតប្រាកដនឹងទទួលបានអត្ថប្រយោជន៏ភ្លាមៗ។ អត្ថប្រយោជន៏ទាំងនេះក៏មានលក្ខណៈប្រយោលផងដែរ ដូចជាបរិស្ថានទូរគមនាគមន៏ដែលមានលក្ខណៈប្រកួតប្រជែងច្រើន នឹងបន្ទាបថ្លៃទូរគមនាគមន៏សំរាប់អ្នករាល់គ្នា។

ដូចដែលយើងបានពន្យល់នៅក្នុងសិក្ខាសាលារបស់យើងជាច្រើននិងកម្មវិធីនានាកាលពីឆ្នាំកន្លងទៅ ការចូលក្នុង WTO មានន័យថាការប្រកួតប្រជែង ហើយនឹងមានអ្នកចាញ់និងអ្នកឈ្នះ។ យើងអាចបែងចែកភាពប្រថុយប្រថាននេះជាពីរៈ អ្នកដែលទទួលរងពីការប្រកួតប្រជែងតាមផ្លូវច្បាប់ និងអ្នកដែលរស់រានដល់សព្វថ្ងៃពឹងផ្អែកលើគោលនយោបាយដែលផ្លាស់ប្តូរ។ ក្រុមហ៊ុនបែបនេះនឹងរួមបញ្ចូលទាំងសហគ្រាសនានាដែលត្រូវបានការពារតាមរយៈអាជ្ញាប័ណ្ណ ឬកូតាដែលនឹងត្រូវផុតកំណត់។ កិច្ចព្រមព្រៀងរបស់ WTO មួយចំនួននឹងជួយដល់ប្រទេសមួយចំនួន និងធ្វើអោយប៉ះពាល់ដល់ប្រទេសមួយចំនួនទៀត។ ឧទាហរណ៏ TRIPS អាចនឹងប៉ះពាល់ដល់អ្នកលក់ស៊ីឌីចំលងខុសច្បាប់នៅក្នុងរយៈពេលខ្លី ក៏ប៉ុន្តែវាជួយដល់តន្រ្តីករកម្ពុជា ឬជនណាម្នាក់ដែលចង់ដាក់ផ្លាកសញ្ញានៅលើផលិតផលមួយក្នុងរយៈពេលវែង។

ជាអ្នកបង្កើតគោលនយោបាយ បញ្ហានេះត្រូវបានធានាថាតុល្យភាពរួម មានលក្ខណៈវិជ្ជមាន។ ការប្រកួតប្រជែងដ៏ត្រឹមត្រូវបង្កើតនូវផលិតភាពដែលជាមូលដ្ឋានគ្រឹះនៃការងារយូរអង្វែង។ ក៏ប៉ុន្តែក្រុមហ៊ុននានានឹងចាំបាច់ត្រូវប្រឹងប្រែងធ្វើការដើម្បីជោគជ័យនៅក្នុងបរិស្ថានបែបនេះ។ វិស័យកាត់ដេរបានកើនឡើងមួយផ្នែកដោយសារតែសិទ្ធិអនុគ្រោះពិសេសចូលទៅក្នុងទីផ្សារសហរដ្ឋអាមេរិកដែលនឹងត្រូវបញ្ចប់នៅក្នុងឆ្នាំ២០០៥ បន្ទាប់ពីនេះ វិស័យនេះចាំបាច់នឹងត្រូវប្រកួតប្រជែងផ្ទាល់ជាមួយនិងទីផ្សារសំលៀកបំពាក់របស់ពិភពលោកដូចជា ប្រទេសចិនដែលឧស្សាហកម្មរបស់គេធំជាងឧស្សាហកម្មកម្ពុជា ២០០ដង។ ជ័យជំនះនឹងពឹងផ្អែកទាំងលើការកែលំអចំពោះបរិស្ថានពាណិជ្ជកម្ម និងកិច្ចប្រឹងប្រែងផ្ទាក់ក្រុមហ៊ុន។ ដំណឹងល្អគឺថាវិស័យឯកជនកម្ពុជានៅក្មេងខ្ចីនិងមានលក្ខណៈសកម្ម ហើយតាមរយៈការបង្កើតបរិស្ថានប្រកួតប្រជែងនាពេលបច្ចុប្បន្ន អាជ្ញាធរបានធានាអះអាងថាវាមិនមែនរីកលូតលាស់ដោយគ្មានប្រសិទ្ធិភាពនោះទេ ដែលប្រទេសដទៃកំពុងតែតស៊ូដើម្បីដោះស្រាយ។ WTO ក៏រួមបញ្ចូលខចែងនានាផងដែរដែលនឹងលប់បំបាត់ចោលនូវកិច្ចព្រមព្រៀងអត្ថ-ប្រយោជន៏កូតា។